## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៣៣ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## បែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤១/៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នសរ/កម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីបែបបទ នីតិវិធី និងយន្តការសម្រាប់ការប្តឹង និងដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ ក្នុងគោលបំណងធានាឱ្យការដោះស្រាយបណ្តឹងតវ៉ាប្រព្រឹត្តទៅដោយសុចរិត យុត្តិធម៌ អព្យាក្រឹត្យ និងគ្មានការរើសអើង ដើម្បីជំរុញឱ្យដំណើរការលទ្ធកម្មសាធារណៈប្រព្រឹត្តទៅដោយរលូន ប្រកបដោយតម្លាភាព គណនេយ្យភាព សុចរិតភាព ការប្រកួតប្រជែង ភាពយុត្តិធម៌ ប្រសិទ្ធភាព សក្តិសិទ្ធិភាព ចីរភាព គុណភាព ការសន្សំសំចៃ និងភាពទាន់ពេល។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់បណ្តឹងតវ៉ាដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែបណ្តឹងតវ៉ាពាក់ព័ន្ធដូចខាងក្រោម៖

- លទ្ធកម្មក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ដែលបានកំណត់រួចជាស្រេចនូវបែបបទ នីតិវិធី និងយន្តការសម្រាប់ដោះស្រាយបណ្តឹងតវ៉ា ដូចមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ ប្រសិនបើកិច្ចព្រមព្រៀងមិនបានកំណត់អំពីបែបបទ នីតិវិធី និងយន្តការសម្រាប់ដោះស្រាយបណ្តឹងតវ៉ាទេ បែបបទ នីតិវិធី និងយន្តការសម្រាប់ដោះស្រាយបណ្តឹងតវ៉ាត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃអនុក្រឹត្យនេះ។
- លទ្ធកម្មដែលត្រូវអនុវត្តតាមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន។
- លទ្ធកម្មដែលប៉ះពាល់ដល់ការសម្ងាត់ក្នុងវិស័យការពារជាតិនិងសន្តិសុខសាធារណៈ ដែលត្រូវមានការសម្រេចពីនាយករដ្ឋមន្ត្រី។

**មាត្រា៣ .-**

និយមន័យនៃបច្ចេកសព្ទដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

- **អ្នកដេញថ្លៃ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងចូលរួមក្នុងលទ្ធកម្មសាធារណៈ និងបានដាក់សំណុំឯកសារស្នើដេញថ្លៃឬការស្នើបញ្ជាក់ពីចំណាប់អារម្មណ៍។
- **អ្នកដែលមានបំណងចូលរួមដេញថ្លៃ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលចង់ចូលរួមក្នុងលទ្ធកម្មសាធារណៈ ដោយបានបញ្ជាក់ពីការចាប់អារម្មណ៍តាមរយៈការស្នើឬការសុំទិញឯកសារកំណត់បុរេលក្ខណសម្បត្តិឬឯកសារដេញថ្លៃ។
- **បណ្តឹងតវ៉ា** សំដៅដល់ការទាមទារឬការតវ៉ារបស់អ្នកដេញថ្លៃអំពីដំណើរការលទ្ធកម្មសាធារណៈដែលមានភាពមិនប្រក្រតីមុនពេលចុះកិច្ចសន្យាលទ្ធកម្ម។
- **អំពើបន្លំ** សំដៅដល់ការបកស្រាយបំភ្លៃហេតុការណ៍ដើម្បីធ្វើឱ្យមានឥទ្ធិពលលើដំណើរការលទ្ធកម្មសាធារណៈ។
- **អំពើឃុបឃិត** សំដៅដល់ផែនការឬការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរឬច្រើននាក់ ដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិតគ្មានលក្ខណៈប្រកួតប្រជែងពិតប្រាកដ ឬធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយ ក្នុងដំណើរការលទ្ធកម្មសាធារណៈឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។



9

- **អំពើបង្ខិតបង្ខំ** សំដៅដល់ការហាមឃាត់ឬការគំរាមកំហែងដោយផ្ទាល់ឬដោយប្រយោលធ្វើឱ្យមានគ្រោះថ្នាក់ដល់បុគ្គលឬទ្រព្យសម្បត្តិរបស់បុគ្គលដើម្បីធ្វើឱ្យមានឥទ្ធិពលដល់ការចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈរបស់បុគ្គលនោះឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

## ជំពូកទី២
## បែបបទនិងនីតិវិធីនៃការដាក់ពាក្យប្តឹងតវ៉ា

**មាត្រា៤ .-**

អ្នកដែលមានបំណងចូលរួមដេញថ្លៃ មានសិទ្ធិប្តឹងតវ៉ាក្នុងដំណាក់កាលនៃការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ និង/ឬដំណាក់កាលនៃការលក់ឬការផ្តល់ឯកសារដេញថ្លៃ ទៅស្ថាប័នអនុវត្តលទ្ធកម្ម។

អ្នកដេញថ្លៃ មានសិទ្ធិប្តឹងតវ៉ាពីភាពមិនប្រក្រតីដែលកើតឡើងក្នុងដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មមុនពេលចុះកិច្ចសន្យា។ ការប្តឹងតវ៉ា ត្រូវធ្វើឡើងតាមលំដាប់លំដោយទៅស្ថាប័នអនុវត្តលទ្ធកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥ .-**

អ្នកដេញថ្លៃ អាចប្តឹងតវ៉ាចំពោះភាពមិនប្រក្រតីណាមួយពាក់ព័ន្ធនឹងករណីជាអាទិ៍៖

- ការកំណត់បុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ
- ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ
- ការលក់ឬការផ្តល់ឯកសារដេញថ្លៃ
- ការទទួលនិងការបើកសំណុំឯកសារស្នើដេញថ្លៃ
- ការមិនអនុញ្ញាតឱ្យអ្នកដេញថ្លៃចូលរួមក្នុងដំណើរការដេញថ្លៃ
- ការសម្រេចប្រគល់កិច្ចសន្យា។

**មាត្រា៦ .-**

អ្នកដេញថ្លៃ មិនអាចប្តឹងតវ៉ាពាក់ព័ន្ធនឹងករណីណាមួយជាអាទិ៍៖

- បណ្តឹងតវ៉ាទាមទារឱ្យមានការពន្យល់ពីមូលហេតុនៃការជ្រើសរើសវិធីសាស្ត្រលទ្ធកម្មនីមួយៗឬពីផែនការលទ្ធកម្ម
- បណ្តឹងតវ៉ា ដែលធ្វើឱ្យមានការកែប្រែ ឬរំខាន ឬបង្អាក់ ឬពន្យារពេលដំណើរការនៃកិច្ចលទ្ធកម្ម
- បណ្តឹងតវ៉ាពុំមានមូលដ្ឋានច្បាប់ច្បាស់លាស់។

**មាត្រា៧ .-**

ពាក្យប្តឹងតវ៉ា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយត្រូវមានចុះហត្ថលេខានិងត្រា ឬស្នាមមេដៃ ឈ្មោះអាសយដ្ឋានរបស់អ្នកប្តឹងតវ៉ា។ អ្នកប្តឹង ត្រូវភ្ជាប់មកជាមួយនូវព័ត៌មានឬឯកសារភស្តុតាងជាលាយលក្ខណ៍អក្សរនិងឯកសារចាំបាច់ផ្សេងៗទៀត។ ពាក្យប្តឹងតវ៉ា ត្រូវបញ្ជាក់អំពីចំណុចសំខាន់ៗ ដូចខាងក្រោម៖

- កម្មវត្ថុនៃការប្តឹង
- ឈ្មោះគម្រោង
- ម្ចាស់គម្រោង
- ភាពមិនប្រក្រតីដែលបានកើតឡើងក្នុងដំណាក់កាលណាមួយនៃកិច្ចលទ្ធកម្ម
- ការរំលោភបំពានលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ និង
- ការស្នើសុំដំណោះស្រាយ។



ᔕ

**មាត្រា៨ ៈ-**

អ្នកដែលមានបំណងចូលរួមដេញថ្លៃ មានសិទ្ធិប្តឹងតវ៉ាមុនរយៈពេល ១០ថ្ងៃ នៃកាលបរិច្ឆេទបញ្ចប់ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ និង/ឬការលក់ឬការផ្តល់ឯកសារដេញថ្លៃ។

អ្នកដេញថ្លៃ ត្រូវប្តឹងតវ៉ាទៅសាមីប្រធានស្ថាប័នអនុវត្តលទ្ធកម្មក្នុងរយៈពេលនៃដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម ឬយ៉ាងយូរបំផុតត្រឹម ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មត្រូវបានបញ្ចប់ លើកលែងតែការប្តឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធផលនៃការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ដែលអនុញ្ញាតឱ្យអ្នកដេញថ្លៃប្តឹងតវ៉ាអំពីលទ្ធផលនៃការដេញថ្លៃ ក្នុងរយៈពេល ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា។

ពាក្យប្តឹងតវ៉ាដែលដាក់ឬផ្ញើមកដល់ស្ថាប័នអនុវត្តលទ្ធកម្ម ក្រោយកាលកំណត់នេះពុំមានសុពលភាពឡើយ។ អ្នកដេញថ្លៃត្រូវចម្លងពាក្យប្តឹងតវ៉ាមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៩ ៈ-**

បណ្តឹងតវ៉ា ត្រូវបានកត់ត្រានិងរក្សាទុកឱ្យបានត្រឹមត្រូវសម្រាប់ពិនិត្យនិងដោះស្រាយ។ ដំណើរការដោះស្រាយបណ្តឹងតវ៉ា គឺជាការសម្ងាត់។

## ជំពូកទី៣
## បែបបទនិងនីតិវិធីដោះស្រាយបណ្តឹងតវ៉ា
### ផ្នែកទី១
### បែបបទនិងនីតិវិធីដោះស្រាយបណ្តឹងតវ៉ាដោយស្ថាប័នអនុវត្តលទ្ធកម្ម

**មាត្រា១០ ៈ-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវដោះស្រាយនិងសម្រេចអំពីបណ្តឹងតវ៉ារបស់អ្នកដែលមានបំណងចូលរួមដេញថ្លៃ ក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ា។

**មាត្រា១១ ៈ-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវដំណើរការលទ្ធកម្មសាធារណៈជាធម្មតា ទោះបីជាមានការប្តឹងតវ៉ាពាក់ព័ន្ធនឹងភាពមិនប្រក្រតីណាមួយដែលបានកើតឡើងក្នុងដំណាក់កាលមុនចុះកិច្ចសន្យា។ ក្នុងករណីមានការប្តឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធផលនៃការវាយតម្លៃប្រគល់កិច្ចសន្យា សាមីស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពន្យារពេលនៃការចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្ម រហូតដល់បណ្តឹងតវ៉ា ត្រូវបានដោះស្រាយចប់នៅសាមីស្ថាប័នអនុវត្តលទ្ធកម្ម និង/ឬនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២ ៈ-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវដោះស្រាយបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃតាមរយៈគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម។ ក្នុងករណីចាំបាច់ ប្រធានស្ថាប័នអនុវត្តលទ្ធកម្មអាចបង្កើតគណៈកម្មការចំពោះកិច្ចមួយ ដោយអញ្ជើញមន្ត្រីជំនាញនៃអង្គភាពពាក់ព័ន្ធក្រោមឱវាទ ចូលរួមផ្តល់យោបល់ក្នុងការដោះស្រាយបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ។

ប្រធាន អនុប្រធាន និងសមាជិកចូលរួមដោះស្រាយបណ្តឹងតវ៉ា ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌លទ្ធកម្ម។



9

**មាត្រា១៣ .-**

ស្ថាប័នអនុវត្តលទ្ធកម្មមានសិទ្ធិបដិសេធឬទទួលដោះស្រាយបណ្តឹងតវ៉ា ដោយត្រូវជូនដំណឹងដល់អ្នកប្តឹងតវ៉ាក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹងតវ៉ា ដោយត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ តាមរយៈលិខិតអនុសិដ្ឋឬលិខិតប្រគល់ដោយផ្ទាល់ដៃ។

**មាត្រា១៤ .-**

ចំពោះពាក្យប្តឹងតវ៉ាដែលពុំមានព័ត៌មានឬឯកសារភ្ជាប់គ្រប់គ្រាន់ គណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម ត្រូវស្នើឱ្យអ្នកប្តឹងតវ៉ាផ្តល់ព័ត៌មានឬឯកសារភស្តុតាងបន្ថែម ដើម្បីគាំទ្រលើបណ្តឹងនោះក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកប្តឹងតវ៉ាបានទទួលសេចក្តីជូនដំណឹងស្តីពីការទទួលដោះស្រាយបណ្តឹងតវ៉ា។ ក្នុងករណីផុតកាលកំណត់នេះ បណ្តឹងតវ៉ា ត្រូវបដិសេធ។

**មាត្រា១៥ .-**

ការដោះស្រាយបណ្តឹងតវ៉ា ត្រូវធ្វើឡើងដោយគោរពតាមគោលការណ៍ឯករាជ្យ យុត្តិធម៌ ស្មោះត្រង់ និងមិនទទួលឥទ្ធិពល ឬតាមបញ្ជារបស់បុគ្គលណាមួយឡើយ។ ក្នុងករណីចាំបាច់ គណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម អាចអញ្ជើញអ្នកប្តឹងតវ៉ា និង/ឬភាគីពាក់ព័ន្ធមកបំភ្លឺបន្ថែម។ ក្នុងករណីនេះ គណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម ត្រូវជូនដំណឹងដល់អ្នកប្តឹងតវ៉ាឱ្យបានដឹងជាមុនដើម្បីចូលរួម អំឡុងពេលនៃការដោះស្រាយបណ្តឹងតវ៉ា។

**មាត្រា១៦ .-**

ការដោះស្រាយបណ្តឹងតវ៉ា ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃការប្តឹងនិងលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា ដោយរួមបញ្ចូលនូវព័ត៌មានដូចខាងក្រោម៖

- មូលហេតុនៃការប្តឹងតវ៉ា
- ភស្តុតាងពាក់ព័ន្ធក្នុងការពិនិត្យដោះស្រាយបណ្តឹងតវ៉ា
- មូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្នុងការធ្វើសេចក្តីសម្រេច
- សេចក្តីសម្រេច និងវិធានការអនុវត្តបន្ត។

**មាត្រា១៧ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ាក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងពីការទទួលដោះស្រាយបណ្តឹងតវ៉ា។ ក្នុងរយៈពេលនេះ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចាត់ចែងប្រជុំពិភាក្សាដោះស្រាយបណ្តឹងតវ៉ាដោយមានកំណត់ហេតុប្រជុំ។ កំណត់ហេតុប្រជុំ ត្រូវចម្លងជូនគ្រប់សមាជិកដែលបានចូលរួមប្រជុំ។

**មាត្រា១៨ .-**

សេចក្តីសម្រេចលើបណ្តឹងតវ៉ា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយផ្អែកលើច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ សេចក្តីសម្រេចនេះ ត្រូវកំណត់អំពីវិធានការពាក់ព័ន្ធមួយចំនួនដែលអាចមានជាអាទិ៍៖



ꝗ

- ការកែតម្រូវឯកសារដេញថ្លៃ ការកំណត់បុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ការលក់ឬការផ្តល់ឯកសារដេញថ្លៃ ការទទួលសំណុំឯកសារស្នើដេញថ្លៃ ការបើកសំណុំឯកសារស្នើដេញថ្លៃ និងការវាយតម្លៃសំណុំឯកសារស្នើដេញថ្លៃ
- ការផ្លាស់ប្តូរសេចក្តីសម្រេចអនុញ្ញាតឬមិនអនុញ្ញាតឱ្យអ្នកដេញថ្លៃ ចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈ
- ការផ្លាស់ប្តូរសេចក្តីសម្រេចប្រគល់កិច្ចសន្យាជូនអ្នកដេញថ្លៃ។

**មាត្រា១៩ .-**

សេចក្តីសម្រេចស្តីពីការដោះស្រាយបណ្តឹងតវ៉ា ត្រូវផ្សព្វផ្សាយលើគេហទំព័ររបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម យ៉ាងយូរ ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចនេះ។

**មាត្រា២០ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចម្លងជូនសេចក្តីសម្រេចស្តីពីការដោះស្រាយបណ្តឹងតវ៉ាទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចនេះ។

**មាត្រា២១ .-**

អ្នកប្តឹងតវ៉ាដែលមិនយល់ព្រមតាមការសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម មានរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីប្តឹងបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណី មានការប្តឹងតវ៉ាបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អ្នកប្តឹងតវ៉ា ត្រូវចម្លងពាក្យប្តឹងតវ៉ានោះទៅសាមីស្ថាប័នអនុវត្តលទ្ធកម្ម។

## ផ្នែកទី២

## បែបបទនិងនីតិវិធីដោះស្រាយបណ្តឹងតវ៉ាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**មាត្រា២២ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ដើម្បីដោះស្រាយបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ។ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មមានសមាសភាពដូចតទៅ៖

| | | | |
|---|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ប្រធាន |
| ២- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | អនុប្រធាន |
| ៣- | អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | | សមាជិកអចិន្ត្រៃយ៍ |
| ៤- | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | | សមាជិក |
| ៥- | អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | | សមាជិក |
| ៦- | តំណាងលេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម | | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



៩

**មាត្រា២៣ ._**

គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម ត្រូវអញ្ជើញតំណាងសាមីស្ថាប័នអនុវត្តលទ្ធកម្ម និងមានសិទ្ធិអញ្ជើញតំណាងវិស័យឯកជនពាក់ព័ន្ធ អ្នកប្ដឹងតវ៉ាឬភាគីពាក់ព័ន្ធដទៃទៀត ដើម្បីបំភ្លឺឬផ្ដល់យោបល់តាមការចាំបាច់។

**មាត្រា២៤ ._**

គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម ត្រូវមានលេខាធិការដ្ឋានមួយ។ នាយកដ្ឋានត្រួតពិនិត្យ និងដោះស្រាយវិវាទ នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម ដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងាររដ្ឋបាល និងជានាកិច្ចដំណើរការរបស់គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម
- ទទួល កត់ត្រា និងរក្សាទុកឱ្យបានត្រឹមត្រូវបណ្ដឹងតវ៉ារបស់អ្នកដេញថ្លៃ
- ពិនិត្យ និងសិក្សាស្រាវជ្រាវលើបណ្ដឹងតវ៉ា ឯកសារ ព័ត៌មាន និងភស្ដុតាងពាក់ព័ន្ធ
- ធ្វើការជាមួយមន្ត្រីជំនាញពាក់ព័ន្ធនៃក្រសួង ស្ថាប័ន ឬតំណាងវិស័យឯកជនពាក់ព័ន្ធ អ្នកប្ដឹងតវ៉ា ឬភាគីពាក់ព័ន្ធដទៃទៀត ដើម្បីទទួលបានការបំភ្លឺ ឬការផ្ដល់ភស្ដុតាងបន្ថែមសម្រាប់ជាមូលដ្ឋាននៃការរៀបចំរបាយការណ៍ជូនប្រធានគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម
- លើកការស្នើសុំដោះស្រាយបណ្ដឹងតវ៉ាជូនប្រធានគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មពិនិត្យ និងសម្រេច
- រៀបចំរបាយការណ៍រាល់ពេលគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មប្រជុំពិនិត្យដោះស្រាយបណ្ដឹងតវ៉ារបស់អ្នកដេញថ្លៃ។

**មាត្រា២៥ ._**

គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម មានសិទ្ធិបដិសេធ ឬទទួលដោះស្រាយបណ្ដឹងតវ៉ា ដោយត្រូវជូនដំណឹងដល់អ្នកប្ដឹងតវ៉ាតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានបញ្ជាក់មូលហេតុច្បាស់លាស់ក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យប្ដឹងតវ៉ា។

**មាត្រា២៦ ._**

ក្នុងករណី គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មបដិសេធការដោះស្រាយបណ្ដឹងតវ៉ា ឬមិនបានជូនដំណឹងដល់អ្នកប្ដឹងតវ៉ាតាមរយៈពេលកំណត់ក្នុងមាត្រា២៥ នៃអនុក្រឹត្យនេះ អ្នកប្ដឹងតវ៉ាមានសិទ្ធិដាក់ពាក្យប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៧ ._**

ចំពោះពាក្យប្ដឹងតវ៉ាដែលពុំមានព័ត៌មានឬឯកសារភស្ដុតាងគ្រប់គ្រាន់ គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម ត្រូវស្នើឱ្យអ្នកប្ដឹងតវ៉ាផ្ដល់ព័ត៌មាន ឬឯកសារភស្ដុតាងបន្ថែមក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទចេញសេចក្ដីជូនដំណឹងស្ដីពីការទទួលដោះស្រាយបណ្ដឹងតវ៉ា។ ក្នុងករណី ផុតកាលកំណត់នេះ បណ្ដឹងតវ៉ា ត្រូវបដិសេធ។

**មាត្រា២៨ ._**

គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម ត្រូវពិនិត្យនិងដោះស្រាយបណ្ដឹងតវ៉ាក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹងស្ដីពីការទទួលដោះស្រាយបណ្ដឹងតវ៉ា។

**មាត្រា២៩ .-**

ការដោះស្រាយបណ្តឹងតវ៉ា ត្រូវគោរពតាមគោលការណ៍និងត្រូវមានការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃការប្តឹងនិងលទ្ធផលនៃការដោះស្រាយបណ្តឹងដូចមានចែងក្នុងមាត្រា១៥ នៃអនុក្រឹត្យនេះ។ ចំពោះសេចក្តីសម្រេចលើបណ្តឹងតវ៉ាត្រូវអនុលោមតាមមាត្រា១៨ នៃអនុក្រឹត្យនេះ។

**មាត្រា៣០ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបញ្ជូនសេចក្តីសម្រេចស្តីពីការដោះស្រាយបណ្តឹងតវ៉ាទៅអ្នកប្តឹងតវ៉ាមួយច្បាប់ និងសាមីស្ថាប័នអនុវត្តលទ្ធកម្មមួយច្បាប់ ដើម្បីអនុវត្ត។ សេចក្តីសម្រេចស្តីពីការដោះស្រាយបណ្តឹងតវ៉ាត្រូវផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ យ៉ាងយូរ ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចនេះ។

**មាត្រា៣១ .-**

អ្នកប្តឹងតវ៉ាដែលមិនយល់ព្រមនឹងសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចប្តឹងបន្តទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ទណ្ឌកម្ម

**មាត្រា៣២ .-**

អ្នករាជការសាធារណៈគ្រប់លំដាប់ថ្នាក់ដែលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ឬត្រូវបានរកឃើញថាមានការពាក់ព័ន្ធនឹងការប្រព្រឹត្តមិនប្រក្រតីនៅក្នុងដំណើរការនៃការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ត្រូវទទួលទណ្ឌកម្មរដ្ឋបាលស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ទណ្ឌកម្មរដ្ឋបាលនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជាឡើយ។

**មាត្រា៣៣ .-**

អ្នកប្តឹង និងបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំនៅក្នុងដំណើរការនៃការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនិងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

បទល្មើសពុករលួយដូចដែលបានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយដូចមានចែងក្នុងមាត្រា៨០ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៣៤ .-**

អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីបែបបទ និងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



9

**មាត្រា៣៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានសហគ្រាសសាធារណៈ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រធានគ្រប់អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងអភិបាលនៃគណៈអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១២កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែសីហា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ